ESTA 000

## តើអ្វីទៅអាជ្ញាធរទូរគមនាគមន៍សេវាកម្មសង្គ្រោះបន្ទាន់ (ESTA)?

ESTA គឺជាសេវាកម្មលេខសូន្យបីដងរបស់រដ្ឋវិចថូរៀ ហើយផ្តល់ការភ្ជាប់ដ៏សំខាន់រវាងសហគមន៍ក្នុងរដ្ឋ វិចថូរៀ និងទីភ្នាក់ងារផ្តល់សេវាកម្មសង្គ្រោះបន្ទាន់នានារបស់រដ្ឋ។ អាជ្ញាធរនេះផ្តល់សេវាកម្មទទួល និងបញ្ជូនការហៅទូរស័ព្ទទៅកាន់សេវាកម្មសង្គ្រោះបន្ទាន់24ម៉ោង) សម្រាប់ប៉ូលិស អគ្គីភ័យ រថយន្តសង្គ្រោះ និងសេវាកម្មសង្គ្រោះបន្ទាន់របស់រដ្ឋ វិចថូរៀ (VICSES)។

## ពេលណាត្រូវហៅទូរស័ព្ទ លេខសូន្យបីដង

គ្រោះអាសន្នជាស្ថានភាពធ្ងន់ធ្ងរ ចៃដន្យ ហើយនិងជារឿយៗជាស្ថានភាពគ្រោះថ្នាក់មួយដែលតម្រូវឲ្យមានចំណាត់ការជាបន្ទាន់។ គ្រោះអាសន្ននេះរាប់បញ្ចូលទាំងគ្រោះថ្នាក់ដល់ជីវិត សុខភាព និង/ឬផ្ទះសម្បែង។ ឧទាហរណ៍នៃគ្រោះអាសន្ន មួយចំនួនរួមមាន ៖

- គ្រោះថ្នាក់តាមផ្លូវអាកាស រថភ្លើង ឬផ្លូវទឹក
- ប្រតិកម្មអាលែកហ្ស៊ីដែលធ្វើឲ្យពិបាកដកដង្ហើម
- ការហូរឈាម (ធ្ងន់ធ្ងរ)
- ការពិបាកដកដង្ហើម (ឧទាហរណ៍ ជំងឺហឺតធ្ងន់ធ្ងរ)
- ជាតិស្កក្នុងឈាមទាប (សន្លប់/វង្វេងស្មារតី/ធ្វើសកម្មភាពប្លែកៗ)
- ការប្រើថ្នាំហួសកម្រិត
- ការលង់ទឹក
- ការឆក់ភ្លើងអគ្គីសនី/រលាក/គ្រោះថ្នាក់នៅ កន្លែងធ្វើការ
- ការផ្ទុះ ឬក៏ឧប្បត្តិហេតុគ្រាប់បែក
- ការគាំងបេះដូង (សង្ស័យ)
- គ្រោះថ្នាក់ចរាចរ (បង្កឲ្យមានរបួសធ្ងន់ធ្ងរ ឬបញ្ហាចរាចរខ្លាំង)
- ឈឺក្រពះ (ធ្ងន់ធ្ងរ)
- ជំងឺស្ត្រូក (សង្ស័យ)
- ជនជាប់គុន
- របួសធ្ងន់ (របួស)
- ជនសន្លប់
- អំពើហិង្សា (ការវាយតប់/ជម្លោះវាយតប់គ្នា/ឧប្បត្តិហេតុអំពើហិង្សាក្នុងគ្រួសារ)
- អគ្គីភ័យដែលគម្រាមកំហែងដល់ជីវិត ឬផ្ទះសម្បែង
- ឧប្បត្តិហេតុទាក់ទងនឹងសម្ភារៈបង្កគ្រោះថ្នាក់

## ពេលណាត្រូវហៅទូរស័ព្ទ លេខសូន្យបីដង

នៅពេលអ្នកហៅទូរស័ព្ទ លេខសូន្យបីដងជាដំបូង ក្រុមហ៊ុនទូរស័ព្ទ Telstra នឹងសួរអ្នកថាតើអ្នកត្រូវការសេវាកម្មណាមួយ៖ ប៉ូលិស អគ្គីភ័យ ឬរថយន្តសង្គ្រោះ ។

ប្រសិនបើហៅទូរស័ព្ទពីរដ្ឋ វិចថូរៀ ក្រុមហ៊ុននឹងភ្ជាប់អ្នកទៅនឹងមជ្ឈមណ្ឌលទាក់ទងនៅគ្រាអាសន្នមួយរបស់ ESTA។

អ្នកទទួលទូរស័ព្ទរបស់ ESTA នឹងសួរអ្នកជាដំបូងថា៖

*តើអ្នកត្រូវការប៉ូលិស រថយន្តសង្គ្រោះ ឬក្រុមពន្លត់អគ្គីភ័យនៅកន្លែងណា?*

បន្ទាប់មកសួរថា៖

*តើអ្នកមានគ្រោះអាសន្នអ្វីដែរ?*

នៅពេលដែលអ្នកទទួលទូរស័ព្ទរបស់ ESTA ដឹងថាអ្នកត្រូវការជំនួយនៅទីកន្លែងណា និងអ្នកមានគ្រោះអាសន្នអ្វីហើយនោះ អ្នកបញ្ជូនការហៅទូរស័ព្ទរបស់ ESTA ទទួលបានសញ្ញាតាមរយៈប្រព័ន្ធបញ្ជូនតាមម៉ាស៊ីនកុំព្យូទ័រ (CAD) ដោយមាន ព័ត៌មានលម្អិត។ ពួកគេប្រើប្រាស់ព័ត៌មានលម្អិតទាំងនេះដើម្បីបញ្ជូនប៉ូលិស ក្រុមពន្លត់អគ្គីភ័យ ឬក៏រថយន្តសង្គ្រោះ ទៅកាន់ទីកន្លែងកើតហេតុការណ៍។

#Iam000

អ្នកទទួលទូរស័ព្ទនឹងបន្តសួរសំណួរផ្សេងៗដល់អ្នកទៀត។
ការសួរនេះនឹងមិនធ្វើឲ្យមានការយឺតយ៉ាវក្នុងការឆ្លើយតបទៅនឹងការសង្គ្រោះបន្ទាន់ ទេ។
ការសួរនេះនឹងជួយកំណត់ថាតើមានតម្រូវការឧបករណ៍សង្គ្រោះបន្ទាន់បន្ថែមទៀតឬទេ (ឧទាហរណ៍ អង្គភាពសង្គ្រោះសម្រាប់អ្នកជាប់កុន) ឬថាតើអ្នកជំងឺត្រូវការការព្យាបាលបឋមឬទេ
ក្នុងខណៈរង់ចាំការមកដល់របស់សេវាកម្មសង្គ្រោះបន្ទាន់។

សូមបន្តនិយាយទូរស័ព្ទ៖ **សូមកុំបិទទូរស័ព្ទ រហូតដល់អ្នកទទួលទូរស័ព្ទប្រាប់អ្នកឲ្យបិទ។**

Last updated 10/05/2019